**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ត.ផ.ហា.ក.** ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ក្នុងគោលបំណងលើកកម្ពស់បច្ចេកទេសស្តង់ដារ អនាម័យ និងជំនឿទុកចិត្តពីសាសនិកឥស្លាម មកលើផលិតផលហាឡាលកម្ពុជា សម្រាប់ផ្គត់ផ្គង់ដល់ទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា និងជំរុញការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅៈ

- "**ហាឡាល**" ឬ "HALAL" ឬ " حلال " (ជាភាសាអារ៉ាប់) សំដៅដល់វត្ថុណាមួយ ឬសេវាកម្មណាមួយ ដែលអនុញ្ញាតឲ្យប្រើប្រាស់ ឬឲ្យចូលរួម ដោយអាស្រ័យទៅតាមច្បាប់ឥស្លាម។ ពាក្យនេះត្រូវបានប្រើជាទូទៅ ទាក់ទងទៅនឹងផលិតផលម្ហូបអាហារ ផលិតផលសាច់ គ្រឿងសម្អាង ផលិតផលថែរក្សាខ្លួន ឱសថ អាហារបំប៉ន គ្រឿងផ្សំម្ហូបអាហារ និងសម្ភារប្រើប្រាស់ផ្សេងៗទៀត។
- **ផលិតផល** សំដៅដល់ប្រភេទទូទៅនៃមុខទំនិញជាគ្រឿងឧបភោគ បរិភោគ និងសេវាកម្ម ដោយបំពេញបាននូវចំណង់ចំណូលចិត្ត ឬសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់។
- **ផលិតផលហាឡាល** សំដៅដល់ផលិតផលដែលកើតឡើងដោយខ្លួនឯង តាមធម្មជាតិ ឬត្រូវបានផលិតឡើង តាមបច្ចេកទេសស្តង់ដារនៃផលិតផលហាឡាល ដែលមិនផ្ទុយនឹងបញ្ញត្តិរបស់សាសនាឥស្លាម។
- **ផលិតផលហាឡាលកម្ពុជា** សំដៅដល់សេវាកម្ម ការផលិត និងការវេចខ្ចប់ ផលិតផលហាឡាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **សេវាកម្ម** សំដៅដល់ការទទួលធ្វើ ការផ្តល់សិទ្ធិ ឬការអនុញ្ញាតឲ្យប្រើ ឬឲ្យផលចំណេញជាទ្រព្យ ឬកិច្ចការណាមួយទៀត ដោយការហៅរកភាគលាភ ឬផលប្រយោជន៍ផ្សេងទៀត ប៉ុន្តែមិនរាប់បញ្ចូល ការរើសបុគ្គលិកតាមច្បាប់ការងារឡើយ។
- **ការផលិត** សំដៅដល់ការកែច្នៃ លាយ ផ្សំ តម្លើង បង្កើត ឬការប្រែរូបភាព និងមានន័យសរុប ទាំងការប្តូរទ្រង់ទ្រាយ ការកែកុនទ្រង់ទ្រាយ ការចែកចាយ ការវេចខ្ចប់ ឬការរក្សាទុក។
- **ការវេចខ្ចប់** សំដៅដល់ការយកផលិតផលហាឡាលសម្រេចមកវេចខ្ចប់ ស្របតាមបច្ចេកទេសស្តង់ដារនៃផលិតផលហាឡាលកម្ពុជា។
- ចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា សំដៅដល់ចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា ដែលត្រូវបានត្រាស់បង្គាប់តែងតាំងដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## សមាសភាពរបស់ គ.គ.ផ.ហ.ក.

**មាត្រា ៣.-**

**គ.គ.ផ.ហ.ក.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | | ជាប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ០១រូប | ជាអនុប្រធាន |
| - ឥស្សរជន ឥស្លាមជាន់ខ្ពស់ | ០១រូប | ជាអនុប្រធាន |
| - សមាជិក ក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងមហាផ្ទៃ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងយុត្តិធម៌ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងធម្មការ និងសាសនា | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងសុខាភិបាល | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងទេសចរណ៍ | ០១រូប | ជាសមាជិក |
| - តំណាង ក្រសួងព័ត៌មាន | ០១រូប | ជាសមាជិក |
| - អគ្គនាយកកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម | | ជាសមាជិក |
| - តំណាង គណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា | ០១រូប | ជាសមាជិក។ |

សមាសភាពជាក់ស្ដែង ត្រូវតែងតាំងដោយសេចក្ដីសម្រេច របស់រាជរដ្ឋាភិបាល។

## ជំពូកទី ៣
## តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ គ.គ.ផ.ហ.ក.

**មាត្រា ៤.-**

**គ.គ.ផ.ហ.ក.** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវ រៀបចំ និងចងក្រងឯកសារទាំងឡាយឲ្យទៅជាផ្លូវច្បាប់ ស្ដីពីការងារហាឡាលកម្ពុជា និងតាមដានការវិវឌ្ឍការងារហាឡាលកម្ពុជា
- រៀបចំឲ្យមានលក្ខណៈជាប្រព័ន្ធក្នុងការគ្រប់គ្រងផលិតផលហាឡាលកម្ពុជា ជាពិសេសលើការងារត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងជំរុញការនាំចេញ ព្រមទាំងការពារស្លាកសញ្ញាហាឡាលកម្ពុជា
- ផ្ដល់ការឯកភាពលើវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា

- ធ្វើជាអ្នកសម្របសម្រួលក្នុងការកសាងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន
- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលរាល់បញ្ហា ដែលទាក់ទងនឹងការអភិវឌ្ឍផលិតផលហាឡាលកម្ពុជា
- ស្រាវជ្រាវ និងអភិវឌ្ឍលើខ្សែចង្វាក់ផលិតកម្មហាឡាលទាំងមូល
- ទាក់ទាញជំនួយបរទេសដើម្បីគាំទ្រលើផលិតផលហាឡាលកម្ពុជា
- ធ្វើជាមជ្ឈមណ្ឌលផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ដល់អ្នកវិនិយោគ ដែលមានបំណងអភិវឌ្ឍផលិតផលហាឡាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងតាមដាននូវរាល់គម្រោង ដែលពាក់ព័ន្ធនឹងផលិតផលហាឡាលកម្ពុជា
- ចូលរួមក្នុងកិច្ចប្រជុំកម្រិតជាតិ និងអន្តរជាតិ ក៏ដូចជាសន្និសីទនានា ស្តីពី ការអភិវឌ្ឍផលិតផលហាឡាលទូទាំងពិភពលោក
- ធ្វើរបាយការណ៍ និងផ្តល់យោបល់ជាប្រចាំ អំពីបច្ចុប្បន្នភាព និងវឌ្ឍនភាពផលិតផលហាឡាលកម្ពុជា ក៏ដូចជាអំពីព័ត៌មានទីផ្សារនៅក្រៅប្រទេសជូនរាជរដ្ឋាភិបាល
- ធ្វើជាអ្នកសម្របសម្រួលនូវរាល់កិច្ចការទាំងឡាយពាក់ព័ន្ធនឹងការងារហាឡាលកម្ពុជា
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៥.-**

**គ.ត.ផ.ហា.ក.** ត្រូវធ្វើការប្រជុំយ៉ាងតិច ០២(ពីរ)ដង ក្នុង០១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ត.ផ.ហា.ក.** អាចប្រជុំជាវិសាមញ្ញបាន។

សមាជិក **គ.ត.ផ.ហា.ក.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន **គ.ត.ផ.ហា.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេស ដែលពាក់ព័ន្ធអង្គការជាតិ អន្តរជាតិ និងផ្នែកឯកជន ចូលរួមផ្តល់យោបល់បាន។

**គ.ត.ផ.ហា.ក.** អាចមានទីប្រឹក្សាបច្ចេកទេស និងអ្នកជំនាញការជាតិ អន្តរជាតិ មួយចំនួនតាមការចាំបាច់។

**គ.ត.ផ.ហា.ក.** មានសិទ្ធិប្រើត្រារបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា ៦.-**

**គ.ត.ផ.ហា.ក.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលជានាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ត.ផ.ហា.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី ៤
## ក្រុមឯកទេសផលិតផលហាឡាល

**មាត្រា ៧.-**

ត្រូវបានបង្កើតក្រុមឯកទេសផលិតផលហាឡាលដែលស្ថិតនៅក្រោមលេខាធិការដ្ឋាន **គ.គ.ផ.ហា.ក.** ហើយដែលមានភារកិច្ចផ្ដល់យោបល់ទាក់ទងនឹងផលិតផលហាឡាលជូន **គ.គ.ផ.ហា.ក.** ពិនិត្យបច្ចេកទេសស្តង់ដារ និងតាមដានការផ្ដល់សេវាកម្ម ការផលិត ឬការវេចខ្ចប់ផលិតផលហាឡាលកម្ពុជា និង ចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធាន **គ.គ.ផ.ហា.ក.**។

**មាត្រា ៨.-**

ក្រុមឯកទេសផលិតផលហាឡាល ត្រូវដឹកនាំដោយចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា។ សមាសភាពជាក់ស្ដែងរបស់ក្រុមឯកទេសផលិតផលហាឡាលនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.គ.ផ.ហា.ក.**។

**មាត្រា ៩.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមឯកទេសផលិតផលហាឡាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.គ.ផ.ហា.ក.**។

## ជំពូកទី ៥
## ការចេញវិញ្ញាបនបត្របញ្ជាក់
## បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា និងការត្រួតពិនិត្យ

**មាត្រា ១០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងផ្ដល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផល ដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា នៅក្រសួងពាណិជ្ជកម្ម ជាមុន។

ការផ្ដល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផលដោយដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" ក្នុងគោលបំណងចែកចាយ ទោះបីក្នុងគោលដៅធ្វើពាណិជ្ជកម្ម ឬមិនធ្វើពាណិជ្ជកម្ម ដោយពុំមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវហាមឃាត់។

**មាត្រា ១១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានផ្ដល់សេវាកម្ម ផលិត វេចខ្ចប់ ផលិតផលហាឡាល តាមការបញ្ជាក់ពីស្ថាប័នគ្រប់គ្រងហាឡាលនៃប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ហើយដែលមានបំណងផ្ដល់សេវាកម្ម ឬផលិត ឬវេចខ្ចប់ផលិតផលហាឡាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា

នៅក្រសួងពាណិជ្ជកម្ម ជាមុន។

ត្រូវបានហាមឃាត់រាល់ការផ្តល់សេវាកម្ម ការផលិត ការវេចខ្ចប់ផលិតផល ដោយដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ទោះបីជាមានការបញ្ជាក់ពីស្ថាប័នគ្រប់គ្រងហាឡាល នៃប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជា ក៏ដោយ។

**មាត្រា ១២.-**

បន្ទាប់ពីបានទទួលពាក្យស្នើសុំ **គ.ត.ផ.ហា.ក.** ត្រូវសហការជាមួយក្រុមឯកទេសផលិតផលហាឡាល ចុះដល់ទីតាំងផ្តល់សេវាកម្ម ផលិត វេចខ្ចប់ និងទីតាំងពាក់ព័ន្ធដទៃទៀត ដើម្បីត្រួតពិនិត្យទៅលើវត្ថុធាតុដើម ឬទំនិញដែលត្រូវវេចខ្ចប់ ដំណើរការនៃការផ្តល់សេវាកម្ម ផលិត វេចខ្ចប់ និងរបៀបរក្សាទុកផលិតផល។

បែបបទនៃការដាក់ពាក្យស្នើសុំវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

**មាត្រា ១៣.-**

ក្នុងករណីពិនិត្យឃើញថា ការផ្តល់សេវាកម្ម ការផលិត ការវេចខ្ចប់នោះ បានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌវាយតម្លៃគុណភាពផលិតផលហាឡាលរួចហើយ **គ.ត.ផ.ហា.ក.** និងក្រុមឯកទេសផលិតផលហាឡាល ត្រូវចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ឲ្យទៅអ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេលមិនលើសពី ០៣(បី) ខែឡើយ។ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវចេញដោយប្រធានក្រុមឯកទេសផលិតផលហាឡាល និងត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.**។

**មាត្រា ១៤.-**

លក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធាន **គ.ត.ផ.ហា.ក.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមឯកទេសផលិតផលហាឡាល។

ស្លាកសញ្ញា ទម្រង់ និងរយៈពេលនៃសុពលភាព របស់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហា.ក.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមឯកទេសផលិតផលហាឡាល។

តម្លៃសេវា បែបបទសម្រាប់ដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា កម្រៃសេវាផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា និងតម្លៃសេវារដ្ឋបាល ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៥.-**

**គ.ត.ផ.ហ.ក.** មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទ ក្រសួងពាណិជ្ជកម្ម និងអ្នកឯកទេសឲ្យចុះទៅទីតាំងផ្តល់សេវាកម្ម ផលិត វេចខ្ចប់ និងទីតាំងពាក់ព័ន្ធដទៃទៀត ដើម្បីត្រួតពិនិត្យលើបច្ចេកទេសស្តង់ដារផលិតផលហាឡាល។ ក្នុងករណីដែលរកឃើញថា អ្នកផ្តល់សេវាកម្ម អ្នកផលិត អ្នកវេចខ្ចប់ មិនបានអនុវត្តតាមលក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាលទេនោះ **គ.ត.ផ.ហ.ក.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមឯកទេសផលិតផលហាឡាល សម្រេច៖

- ឲ្យធ្វើការកែតម្រូវ
- ដកហូតស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ពីផលិតផល
- ផ្អាកការប្រើប្រាស់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជាមួយរយៈ រហូតដល់មានការកែតម្រូវ
- ដកហូតវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា និងស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ពីផលិតផលជាស្ថាពរ។

ការត្រួតពិនិត្យលើបច្ចេកទេសស្តង់ដារផលិតផលហាឡាលពីសំណាក់ **គ.ត.ផ.ហ.ក.** មិនមែនជាឧបសគ្គដល់ការត្រួតពិនិត្យរបស់សមត្ថកិច្ចផ្សេងទៀត ដែលអនុវត្តភារកិច្ចស្របតាមលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតឡើយ។ ម្ចាស់ផលិតផល នៅតែមានកាតព្វកិច្ចអនុវត្តតាមបទដ្ឋានបច្ចេកទេសស្តង់ដារ អនាម័យ និងបរិស្ថានជាដើម ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា ១៦.-**

**គ.ត.ផ.ហ.ក.** សហការជាមួយអគ្គនាយកកាំកុងត្រូល ដើម្បីចាត់មន្ត្រី ចុះត្រួតពិនិត្យការប្រើប្រាស់ស្លាកសញ្ញា វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា លើផលិតផលនៅកន្លែងស្តុក ឬដែលចរាចរលើទីផ្សារ ឬទីតាំងផ្តល់សេវាកម្ម។

អគ្គនាយកកាំកុងត្រូល ត្រូវចាត់តាំងមន្ត្រី ចុះត្រួតពិនិត្យការប្រើប្រាស់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា លើផលិតផលនៅកន្លែងស្តុក ឬដែលចរាចរលើទីផ្សារ ឬទីតាំងផ្តល់សេវាកម្ម និង ផលិតផលហាឡាលនាំចូល។

## ជំពូកទី ៦
## ប្រភពធនធានរបស់ គ.ត.ផ.ហ.ក.

**មាត្រា ១៧.-**

**គ.ត.ផ.ហ.ក.** មានប្រភពថវិកាជាតិដែលជាឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម។ **គ.ត.ផ.ហ.ក.** ត្រូវបើកគណនីមួយនៅរតនាគារជាតិ។

**គ.ត.ផ.ហ.ក.** មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីជាធរមាន នូវមូលនិធិជំនួយដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**គ.ត.ផ.ហ.ក.** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីប្រភពហិរញ្ញប្បទាន

សហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត ដែលបម្រើដល់ការអនុវត្តការងាររបស់ខ្លួន។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១៨.-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ឬការដកហូតស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ពីផលិតផល
- ការព្យួរ ឬការដកហូតវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា
- ការពិន័យអន្តរការណ៍។

ទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាប្រធាន **គ.ត.ផ.ហ.ក.**។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី លើកលែងតែទណ្ឌកម្មពិន័យអន្តរការណ៍។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រមូលប្រាក់ចំណូល ដែលបានមកពីការពិន័យ ចំពោះអំពើល្មើសដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ១៩.-**

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវបង្គាប់ឲ្យមន្ត្រីកាំកុងត្រូលមានសមត្ថកិច្ច កសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណជនល្មើស រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវបង្គាប់ឲ្យមន្ត្រីកាំកុងត្រូលមានសមត្ថកិច្ច ស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច រឹបអូសវត្ថុតាងនៃបទល្មើស។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹង ចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទៅតុលាការរដ្ឋបាលវេណីមានសមត្ថកិច្ច។

**មាត្រា ២០.-**

អំពើក្លែងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ឬក្លែងស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា ២១.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤,០០០,០០០ (បួនលាន) រៀល ចំពោះអំពើផ្តល់សេវាកម្ម ឬផលិត ឬវេចខ្ចប់ផលិតផលដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ទោះបីជាមាន ឬគ្មានការបញ្ជាក់ពីស្ថាប័នគ្រប់គ្រងហាឡាលនៃប្រទេសណាមួយក្តី។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២២.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤,០០០,០០០ (បួនលាន) រៀល ចំពោះអំពើផលិត ឬវេចខ្ចប់ផលិតផល ឬសេវាកម្មដោយបន្តដាក់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា លើផលិតផល បន្ទាប់ពីស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ត្រូវបានព្យួរ ឬដកហូត។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៣.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤,០០០,០០០ (បួនលាន) រៀល ចំពោះអំពើផលិត ឬវេចខ្ចប់ផលិតផល ឬសេវាកម្ម ដោយបន្តដាក់ស្លាកសញ្ញាវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជាលើផលិតផល បន្ទាប់ពីវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជាអស់សុពលភាព ឬត្រូវបានព្យួរ ឬដកហូត។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល ០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៤.-**

នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២១ ដល់មាត្រា ២៣ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០,០០០,០០០ (ដប់លាន) រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៥.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២,០០០,០០០ (ពីរលាន) រៀល ចំពោះអំពើផលិត វេចខ្ចប់

ផលិតផល ឬសេវាកម្មផលិតផលហាឡាលកម្ពុជា ដោយរំលោភលើលក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៦**.-

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៥ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៥,០០០,០០០ (ប្រាំលាន) រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ក្នុងអំឡុងពេល០២ (ពីរ)ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា ២៧**.-

ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលចំពោះមន្ត្រី និងបុគ្គលណាដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យបច្ចេកទេសស្តង់ដារផលិតផលហាឡាល បានរកឃើញថា ការផ្តល់សេវាកម្ម ឬផលិត ឬវេចខ្ចប់ផលិតផលហាឡាល ដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" ដោយពុំមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ឬវិញ្ញាបនបត្រនេះត្រូវបានអស់សុពលភាព ឬត្រូវបានដកហូត ឬដោយមិនបានអនុវត្តតាមលក្ខខណ្ឌវាយតម្លៃបច្ចេកទេសស្តង់ដារហាឡាលកម្ពុជា ហើយមិនបានរាយការណ៍មក **គ.ត.ផ.ហា.ក**. ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលចំពោះមន្ត្រី និងបុគ្គលណាដែលចុះត្រួតពិនិត្យបច្ចេកទេសស្តង់ដារផលិតផលហាឡាលដោយពុំមានលិខិតបញ្ជាបេសកកម្មពី **គ.ត.ផ.ហា.ក**. ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ២៨**.-

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានផ្តល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ "حلال" ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា នៅក្រសួងពាណិជ្ជកម្ម ក្នុងអំឡុងពេល ០៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចេញអនុក្រឹត្យនេះ។ បើផុតអំឡុងពេលនេះ ហើយរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ នៅតែមិនព្រមមកបំពេញបែបបទដាក់ពាក្យស្នើសុំទៀត នោះចាត់ទុកថា ផលិតផលទាំងនោះជាផលិតផលខុសច្បាប់ ហើយប្រឈមមុខនឹងការចាត់វិធានការតាមអនុក្រឹត្យនេះ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានផ្តល់សេវាកម្ម ផលិត វេចខ្ចប់ផលិតផល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដាក់សញ្ញា ឬស្លាក "**ហាឡាល**" ឬ "HALAL" ឬ " حلال " តាមការបញ្ជាក់ ពីស្ថាប័នគ្រប់គ្រងហាឡាលនៃប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវអនុវត្តតាមវាក្យខណ្ឌទី១ ខាងលើនេះផងដែរ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២៩**.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣០**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ និងចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<ins>**កន្លែងទទួល**</ins>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣០.-
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ